# រឿង មហាចោរនៅទល់ដែន

## ភាគទី៤៤ (ស្នេហាលើទូក)

ពាក្យនេះ ក៏ត្រូវគេខ្សឹបគ្នាជាលំដាប់។

មាននុស្សុះរឹងទៅលើមើលតាមបង្អួចទៅក្រៅ។ ឃើញកាមាចាប់សេះមួយបំផាយទៅទិសខាងលិច។ បុរសស្ទុះទៅក្នុងបន្ទប់មួយទៀត ជួបព្រះនាងខត្តិយាណី ដែលលាន់មាត់ថា:

មាននុភាំងស្មារតីពីមុខចំណាប់ផុតអស់ស្រីនេះ។

អើ! ពេលនេះជាពេលប្រសើរណាស់។ យើងជួបគ្នាតែក្នុងពេលអាសន្នហ្ន៎!

នាងមណីខាំធ្មេញសម្លឹងមុខមាននុ។

មាននុស្ទុះភ្លែតទៅចាប់នាងលើកបីរត់ចេញតាមមាត់ទ្វារសំដៅទៅឯមាត់កំពង់។

នាងមណីប្រឹងបម្រះយ៉ាងណាក៏ចេញមិនរួចឡើយ។

លុះទៅដល់ក្នុងទូកថ្ងៃមួយ ដែលជាទូករបស់ព្រះកម្ពុត មាននុទម្លាក់នារីវរលក្ខណ៍ប្រុស រួចចាក់សោគ្រឹប។ នាយកោបមកដល់ជាបន្ទាន់នោះដែរ។ មាននុប្រាប់នាយកោបថា:

ហៅគ្នាយើង រើសដើងឯកឲ្យបានដប់នាក់មកធាប់។

ខាងលើអារុណ មហាកាល វាយថយធ្លាយមកក្រោពាសវាល។

គាប់ជួនពេលនោះ ពួករទេះក៏មកដល់ទៀត។ ការវាយប្រឡូកក៏មានឡើងយ៉ាងពិស្ដារ។

កងទាហានលុះបានឃើញខ្មាំងច្រើនពេក ក៏ថយរត់ចូលបន្ទាយវិញចាក់សោរឥតបង្អង់។

អារុណសើចគ្រហាញដាក់មាត់ទ្វារ ដែលបិទជិតស្លុង រួចបញ្ជាឲ្យពលប្រជាជន និងពលអ្នកទោសថយខ្លួនថយទៅភូមិភ្លៀត។

ក្នុងរាំងនទងងឹតនៃពសុជា ទូកថ្ងៃបោះពួយយ៉ាងលឿនបណ្ដោយទឹកទៅតាមខ្សែទឹក។ ក្នុងផ្ទៃងងឹតនេះ វាសនាព្រះនាងខត្តិយាណីក៏ងងឹតដែរ។ បីម៉ោងមុននេះ វាសនាព្រះ

នាងភ្លឺត្រចះត្រចង់ល្អ តែពេលនេះនាងមកបង្ខំជាន់ពន្ធិចឲ្យងងឹតស្អុងវិញ។ ដោយហេតុនេះហើយបានជាមានពាក្យបុរាណចារ្យនិទានថា:

"ឃ្មោកលិច អំបែងអណ្តែត កង់ត្រាច កង់ធ្ងន់"

បើវដ្តសង្សារតាក់តែងមនុស្សឲ្យវិលចុះវិលឡើងយ៉ាងនេះ តើមនុស្សចេះតែនៅចង់ចិត្តប្រកាន់តែខ្ពស់មិនសមហេតុមិនសមផលឬអ្វី?

ខាងលើដំបូល មាននន្ទដែលអស់កម្លាំងដេកគងថ្វាសមើលផ្កាយនៅជិតអ្នក គឺមហាកាលម្ចាស់អារុណម្ចាស់។ ខាងមុខនាយកោប វីរៈ និងបំរុងចែវយ៉ាងមាំមួន។ កូនទាហានឈ្មោះបង្រួលកាន់កន្សែ។ ខាងក្នុងទូកក្នុងបន្ទប់ដែលបិទជិតចាក់សោ គឺព្រះនាងខត្តិយាណីស្រីជាប់ទោស។

នាងគេងលើគ្រែមួយ មានពូកយ៉ាងស្អាត បីដូចក្នុងបន្ទប់គេងរបស់នាង។ ចង្កៀងប្រេងកាតតូចមួយបំភ្លឺវត្ថុនានាដែលល្អ។ ឃើញចាំងនឹងភ្នែក មានកែវទឹក ផ្តិលប្រាក់ កញ្ចក់ស្និត កែវម្សៅ ដបទឹកអប់ជាដើម។ នារីគេងពុំលក់ទេ ត្បិតពុំដឹងថាមាននន្ទធ្វើបាបនាងវិញយ៉ាងណាវិញ ដោយក្តៅស្អុះពេក នាងក្រោកទៅបើកបង្អួច។ ទេ! បង្អួចបិទជិតពីក្រៅ។ នាងញញឹមដោយឃើញថាគុករបស់មាននន្ទជាគុកមួយដែលរសាត់តាមខ្សែទឹកហើយដៃឃ្វេងឃ្វាង។ ចេះតែលឿនទៅមុខជាដរាប។ ម្យ៉ាងទៀត គុកនេះសមសួនមែន ត្បិតមានពូកដេកផង។ នារីនឹកថា គុកចោរគ្រាន់បើជាងគុកអ្នករាជការដែរ។ ធីតាហៀបនឹងដើរទៅទម្រេតលើពូកវិញ ស្រាប់តែឮសូរមាត់មាននន្ទ និងកងសហជីវិននិយាយគ្នារអ៊ូខាងលើដំបូលទូក។ កញ្ញាអរព្រួចផ្ទៀងត្រចៀកស្តាប់ឮមាននន្ទនិយាយរវើយៗ ដោយអស់កម្លាំងថា:

ស្អែកល្ងាចយើងទៅដល់មាត់ទន្លេមែនទេ?

មហាកាលឆ្លើយ:

បាទ! បើយ៉ាងយូរយប់ចុះ។

ព្រះនាងខត្តិយាណីបើកភ្នែកធំៗ ដឹងថាគេនាំខ្លួនផុតពីទល់ដែនសៀមជាប្រាកដ។ មាណវីព្រឺក្បាលខ្វាកៗ។ រួចពីនោះគឺសំឡេងអារុណដែលនាងពុំភ្លេច ដែលអធិប្បាយប្រាប់មាននន្ទ

*អំពីកាលខ្លួនមកដល់ភូមិភ្នៀតរួចបានឃើញប្រកាសក៏លាមក រួចបានវាយប្រឡូកក្នុងអសនៈព្រះកម្ពុត។ គួរកោតសរសើរដល់ស្នាដៃ និងសេចក្ដីវាងវៃក្នុងការប្រយុទ្ធរបស់បុរសនេះមែន។ ក្រោយមក មានទូបញ្ជាថាៈ*

*ឲ្យផ្លាស់គ្នាកាច់ចង្កូតម្ដងម្នាក់ៗ។ ម្នាក់កាច់ចង្កូតចំនួនបីម៉ោងទាំងមេ ទាំងកូន។ ឥឡូវឈប់ចែវនាំគ្នាដេកចុះ។*

*អ្នកពាល់គ្នាស្រែកហ៊ោក្រេវ សប្បាយនឹងកិច្ចបញ្ជានេះ។*

*មានទូបន្តកិច្ចបញ្ជាទៅទៀតថាៈ*

*ក៏ប៉ុន្តែ កោប។*

*បាទ!*

*ហ៊ឺ! យកកូនសោនេះទៅចាក់បន្ទប់ក្នុងទូកមើល។ រួចសួរប្អូនខ្ញុំថា ត្រូវការអ្វីខ្លះ? នែ! កុំមើលងាយណ៎ា! តោងគួរសមនឹងគេជានិច្ចព្រោះយើងមិនទាន់ឃើញទោសគេទេ។ នែ! ...កុំភ្លេចបម្រើទឹកក្ដៅគេផង។*

*មហាកាល និងអារុណទះដៃផូងៗ សើចយ៉ាងសប្បាយ រួចលួចនិយាយថាៈ*

*អាកោបមានសំណាងណាស់វើយ!*

*មានទូឮដូច្នោះ លួចសើចក្នុងកំភួនដៃដែលអ្នកដាក់លើមុខអ្នក រួចធ្វើមិនឮនឹងពាក្យលេងនេះ។*

*នាយកោបធ្វើមុខក្រញូវ លួចសម្លក់មហាកាល និងអារុណ រួចទះក្បាលបង្រួល ដែលកាច់ចង្កូតមួយផ្លូង លោតចុះទៅចាក់សោទ្វារ។*

*នាងខត្តិយាណីស្ទុះទៅទម្រេតខ្លួនលើគ្រែធ្វើព្រងើយ។ ទ្វាររបើកឡើង។ នាយកោបឱនខ្លួនធ្វើគារវកិច្ចពីមុខនារី។ នាងងក់ក្បាលចោលញញឹមយ៉ាងស្រស់ដាក់នាយកោប ដែលធ្វើឲ្យនាយកោបឈ្ងុលអួលៗក្នុងចិត្ត និយាយឡើងញ័រថាៈ*

**(*សូមរង់ចាំតាមដានភាគទី៤៥ នៅសប្ដាហ៍ក្រោយ*)**

*អត្ថបទដោយ៖ មាស សុភាព*